positive partnerships

Working together to support school-aged students on the autism spectrum

# ខិត្តប័ណ្ណព័ត៌មាន



Khmer - What is autism?

## តើអូទីហ្សឹមជាអ្វី?

**អូទីហ្សឹមគឺជាភាពខុសគ្នានៅក្នុងការអភិវឌ្ឍន៍របស់បុគ្គលម្នាក់ ដែលប៉ះពាល់ដល់របៀបដែលពួកគេរៀនសូត្រ និងប្រាស្រ័យទាក់ទងជាមួយអ្នកឯទៀត ហើយនិងបរិយាកាសជុំវិញពួកគេ។**



មនុស្សអូទីហ្សឹមអាចមានភាពស្រដៀងគ្នាខ្លះៗ ប៉ុន្តែពួកគេទាំងអស់សុទ្ធតែមានភាពខុសប្លែកពីគ្នា ហេតុនេះហើយវាត្រូវបានគេហៅថា ‘អាការអូទីហ្សឹម’ ឬ ‘autism spectrum’។

មនុស្សវ័យក្មេងមួយចំនួនដែលមានអាការអូទីហ្សឹម មានឯករាជ្យភាពខ្លាំង ខណៈពេលអ្នកផ្សេងទៀតទទួលអត្ថប្រយោជន៍ពីការគាំទ្រនៅផ្ទះ នៅសាលារៀន និងនៅក្នុងសហគមន៍។

មនុស្សទាំងអស់ដែលមានអាការអូទីហ្សឹមនឹងមានចំណុចខ្លាំង និងចំណាប់អារម្មណ៍ខុសៗគ្នា។

មនុស្សអូទីហ្សឹមអាចត្រូវការជំនួយជាមួយនឹង៖

- ការប្រាស្រ័យទាក់ទង
- ទំនាក់ទំនងសង្គម
- ដំណើរការយល់ដឹងខាងវិញ្ញាណ
- មុខងារប្រតិបត្តិ (ការធ្វើផែនការ និងការរៀនសូត្រ)
- ការថែរក្សាខ្លួនឯង និងឯករាជ្យភាព

ចូលទៅកាន់គេហទំព័រ **positivepartnerships.com.au**

The Positive Partnerships initiative is funded by the Australian Government Department of Education through the Helping Children with Autism Package. The views expressed in this publication do not necessarily represent the views of the Australian Government or the Australian Government Department of Education.

# តើមានមនុស្សអូទីហ្សឹមប៉ុន្មាននាក់ ហើយតើគេធ្វើរោគវិនិច្ឆ័យអូទីហ្សឹមដោយរបៀបណា?

**ការស្រាវជ្រាវបច្ចុប្បន្នបានបង្ហាញថាក្នុងក្រុមមនុស្ស 100 នាក់ មាន 1 ឬ 2 នាក់ជាមនុស្សអូទីហ្សឹម។ មនុស្សអាចធ្វើរោគវិនិច្ឆ័យក្នុងវ័យក្មេង ឬពេលចាប់ផ្ដើមចូលវ័យចំណាស់។**



ទាំងក្មេងប្រុស និងក្មេងស្រីអាចមានអាការអូទីហ្សឹម ប៉ុន្តែក្មេងប្រុសគឺប្រហែលជា 3 ដងច្រើនជាងក្មេងស្រីត្រូវបានធ្វើរោគវិនិច្ឆ័យមានអូទីហ្សឹម ដែលបច្ចុប្បន្ននេះយើងសម្គាល់ឃើញមានអូទីហ្សឹមកាន់តែច្រើននៅក្នុងចំណោមក្មេងប្រុស។

ការស្រាវជ្រាវបង្ហាញថាស្ថានភាពបរិស្ថាន និងកត្តាហ្សែន ដើរតួនាទីធ្វើឱ្យបុគ្គលម្នាក់ជាមនុស្សអូទីហ្សឹម។

ដើម្បីវាយតម្លៃកូនរបស់អ្នករកមើលអូទីហ្សឹម សូមពិគ្រោះជាមួយវេជ្ជបណ្ឌិតព្យាបាលរោគទូទៅ (G.P.) របស់អ្នក ឬគ្រូពេទ្យកុមារ។ ជាញឹកញាប់ ការវាយតម្លៃនឹងត្រូវធ្វើឡើងដោយអ្នកជំនាញសុខភាពពីរ ឬបីនាក់ដែលសង្កេតមើលកូនរបស់អ្នក ហើយនិយាយជាមួយពួកគេ និងគ្រួសាររបស់អ្នក។

មនុស្សអូទីហ្សឹមគឺជាផ្នែកនៃវប្បធម៌ និងសហគមន៍នីមួយៗជុំវិញពិភពលោក។

positive partnerships

Working together to support school-aged students on the autism spectrum



# Fact Sheet

## What is Autism?

**Autism is a difference in a person's development that affects how they learn and interact with others and their surroundings.**



Autistic people may have some similarities but they are all different to each other, which is why it is called the 'autism spectrum'.

Some young people on the autism spectrum are very independent, while others benefit from support at home, at school and in the community.

All people on the spectrum will have different strengths and interests.

Autistic people may need support with:

- Communication
- Social interaction
- Sensory processing
- Executive functioning (planning and learning)
- Self-care and independence

Go to **positivepartnerships.com.au**

The Positive Partnerships initiative is funded by the Australian Government Department of Education through the Helping Children with Autism Package. The views expressed in this publication do not necessarily represent the views of the Australian Government or the Australian Government Department of Education.

# How many people are autistic and how is autism diagnosed?

**The current research suggests that within a group of 100 people, 1 or 2 of them will be autistic. People can be diagnosed early or later in life.**



Both boys and girls can be on the spectrum, but boys are 3 times more likely than girls to be diagnosed as we currently recognise autism more in boys.

Research indicates that environmental conditions and genetic factors play a role in a person being autistic.

To have your child assessed for autism, talk to your General Practitioner (G.P.) or paediatrician. An assessment will often be completed by two or three health professionals observing your child and talking with them and your family.

Autistic people are part of every culture and community around the world.